**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ...០៥...សរ..

# សារាចរ

## ស្តីពី

## ការប្រើកាលបរិច្ឆេទទាំងចន្ទគតិ ទាំងសុរិយគតិ ក្នុងលិខិតបទដ្ឋានគតិយុត្តនិងលិខិតរដ្ឋបាល

ក្នុងពេលកន្លងមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា ការប្រើកាលបរិច្ឆេទទាំងចន្ទគតិ ទាំងសុរិយគតិក្នុងលិខិតបទដ្ឋានគតិយុត្តនិងលិខិតរដ្ឋបាលរបស់ក្រសួង ស្ថាប័ន នៅពុំទាន់មានឯកភាពស៊ីចង្វាក់គ្នាបានល្អនិងរលូននៅឡើយ។ ដើម្បីឱ្យការប្រើកាលបរិច្ឆេទទាំងចន្ទគតិ ទាំងសុរិយគតិក្នុងរូបមន្តបញ្ចប់នៃលិខិតបទដ្ឋានគតិយុត្តនិងក្បាលលិខិតឬរូបមន្តបញ្ចប់នៃលិខិតរដ្ឋបាលឬឯកសារផ្សេងទៀតមានឯកភាព រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅ៖

**១- លិខិតបទដ្ឋានគតិយុត្ត** ត្រូវសរសេរថា

"ថ្ងៃ... ខែ... ឆ្នាំ... ...ស័ក ព.ស...." (ចន្ទគតិ)

"ធ្វើនៅ... ថ្ងៃទី... ខែ... ឆ្នាំ..." (សុរិយគតិ)។

ឧទាហរណ៍ :

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ (ចន្ទគតិ)

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ (សុរិយគតិ)។

**២- លិខិតរដ្ឋបាលឬឯកសារផ្សេងទៀត** ត្រូវសរសេរថា

"ថ្ងៃ... ខែ... ឆ្នាំ... ...ស័ក ព.ស...." (ចន្ទគតិ)

"... ថ្ងៃទី... ខែ... ឆ្នាំ..." (សុរិយគតិ)។

ឧទាហរណ៍ :

ថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ (ចន្ទគតិ)

រាជធានីភ្នំពេញ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ (សុរិយគតិ)។

ដោយឡែក លិខិតទំនាក់ទំនងជាមួយបរទេស ត្រូវប្រើតែកាលបរិច្ឆេទតាមសុរិយគតិប៉ុណ្ណោះ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នត្រូវផ្សព្វផ្សាយនិងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១១ រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៧

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ